# សន្និសីទស្រាវជ្រាវថ្នាក់ជាតិលើកទី១ ឆ្នាំ២០២៦

## តួនាទីសេវានិស្សិតក្នុងការជំរុញការអភិវឌ្ឍបុគ្គលិកលក្ខណៈ និងការចូលរួមក្នុងសង្គមនាយុគសម័យឌីជីថល÷ ករណីសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា

បណ្ឌិត មឿន ចន្ទ្រា





# មាតិកា


- មូលន័យសង្ខេប
- សេចក្តីផ្តើម
- រំលឹកទ្រឹស្តី
- វិធីសាស្ត្រស្រាវជ្រាវ
- លទ្ធផលនិងពិភាក្សា
- សេចក្តីសន្និដ្ឋាន
- ឯកសារយោង




# មូលន័យសង្ខេប

# មូលន័យសង្ខេប

អត្រាបោះបង់ការសិក្សានៅឧត្តមសិក្សាផ្ដល់ផលជះអវិជ្ជមានដល់និស្សិត និងសង្គមទាំងមូល។ ប៉ុន្តែការសិក្សាពីស្ថានភាពសេវានិស្សិត ជាពិសេសការផ្ដោតលើតួនាទីសេវានិស្សិតមិនទាន់មានការយកចិត្តទុកដាក់ និងមានកង្វះចន្លោះការស្រាវជ្រាវ។ ការស្រាវជ្រាវមានគោលបំណងរកឱ្យឃើញតួនាទីសេវានិស្សិតក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។ ការស្រាវជ្រាវបានជ្រើសរើសយកវិធីសាស្ត្របែបគុណវិស័យ ដោយជ្រើសរើសសំណាកតាមវិធីសាស្ត្រលក្ខណៈវិនិច្ឆ័យជាមុនសរុបចំនួន ៩៧នាក់។ ទិន្នន័យប្រមូលពីការសម្ភាសបានយកមកវិភាគតាមវិធីសាស្ត្រវិភាគបែបប្រធានបទមានពីរ គឺប្រធានបទទទួលបានតាមរយៈក្របខណ្ឌទ្រឹស្ដី ជាមួយក្របខណ្ឌអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ និងប្រធានបទកើតឡើងនៅកំឡុងពេលសម្ភាសន៍។ លទ្ធផលស្រាវជ្រាវបានបង្ហាញថាសេវានិស្សិតមានតួនាទី÷ (១) អភិវឌ្ឍជំនាញ (២) សមត្ថគុណចាំបាច់ (៣) គោលដៅនិងផែនការអាជីព (៤) ជំនាញទន់ (៥) បន្ថយការបោះបង់ការសិក្សា (៦) ភាពអ្នកសិក្សាពេញមួយជីវិត (៧) ការទទួលខុសត្រូវសង្គម និង (៨) អភិវឌ្ឍភាពជាខ្មែរ។ លទ្ធផលការសិក្សាស្រាវជ្រាវនេះក៏បានស្នើ និងផ្ដល់អនុសាសន៍ដល់ភាគីពាក់ព័ន្ធអនុវិស័យឧត្តមសិក្សាការបង្កើនកិច្ចយកចិត្តទុកដាក់ លើសេវានិស្សិតឱ្យបានជាអតិបរម៉ា ដើម្បីឈានទៅរួមចំណែកកសាងមូលធនមនុស្សកម្ពុជាក្លាយជាសង្គមពុទ្ធិ និងចក្ខុវិស័យឆ្នាំ២០៥០។



# សេចក្ដីផ្ដើម

# តួនាទីគ្រឹះស្ថានឧត្តមសិក្សា និងវត្តមានសេវានិស្សិត

- ការអប់រំត្រូវបានកំណត់ និងទទួលស្គាល់ជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច នវានុវត្តន៍ និងការរីកចម្រើននៃសង្គម (Altbach & Knight, 2007) និងកំពុងដើរតួនាទីសំខាន់ណាស់លើការបណ្តុះបណ្តាលមូលធនមនុស្ស ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ (អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ [UNESCO], 2017)
- ក្រៅពីការផ្លាស់ប្តូរលើកម្រិតគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និន្នាការនេះបានជំរុញដោយការផ្លាស់ប្តូរប្រជាសាស្ត្រនិស្សិត និងតម្រូវការក្នុងការដោះស្រាយតម្រូវការរបស់និស្សិតផង(Komives et al., 2003; Nuss, 2003)។ ទន្ទឹមនេះ Gunder and Shellgren (2022) បានសង្កត់ធ្ងន់ថាគុណភាពអប់រំឧត្តមសិក្សារួមបញ្ចូលទាំងការសម្របសម្រួល និងការផ្តល់បរិស្ថានគាំទ្រយ៉ាងសកម្មដល់និស្សិតក្នុងការកសាងវប្បធម៌សិក្សាពេញមួយជីវិត និងបរិយាបន្ន។
- ស្របគ្នានេះ ការយកចិត្តទុកដាក់លើការរក្សានិស្សិត និងភាពជោគជ័យលើការសិក្សា ជំរុញឱ្យគ្រឹះស្ថានឧត្តមសិក្សាបង្កើនការរៀបចំសកម្មភាពគាំទ្រ និងជួយដោះស្រាយបញ្ហា (Bailey et al., 2015; Cooper, 2010)។
- សេវានិស្សិតត្រូវបានទទួលស្គាល់ផងដែរទូទាំងពិភពលោកដែលប្រធានបទនេះត្រូវបានលើកឡើងជាញឹកញាប់ក្នុងសន្និសីទ និងកិច្ចប្រជុំផ្សេងៗ (UNESCO, 1998, 2009)។

# ចំណោទបញ្ហា និងគោលបំណងនៃការស្រាវជ្រាវ

- អង្គការកិច្ចការនិស្សិតគ្រឹះស្ថានឧត្តមសិក្សា និងអង្គការអន្តរជាតិសម្រាប់កិច្ចការនិស្សិតនិងការប្រឹក្សា (NASPA, 2015) ស្របពេលកម្រិតតំបន់វិញក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ក្រោមក្របខណ្ឌបណ្ដាញសាកលវិទ្យាល័យអាស៊ាន (ASEAN University Network [AUN]), 2025)។
- ការស្រាវជ្រាវនៅអនុវិស័យឧត្តមសិក្សាលើប្រធានបទសំខាន់មួយចំនួនរួមមានអភិបាលកិច្ច (Un & Sok, 2018) ជំនួយបរទេស (Dy, 2015) បច្ចេកវិទ្យា (Heng, 2021; Heng & Doeur, 2022 ; Ly & Doeur, 2024) ការអនុវត្តសេវានិស្សិត (Moeurn, 2025a) ធនធានមនុស្ស ( Rana et al., 2017) ការស្រាវជ្រាវ (Heng et al., 2023, 2024) ភាគីពាក់ព័ន្ធ (Sam & Dahles, 2017) ការអភិវឌ្ឍ (Heng, 2024) និងអន្តរជាតូបនីយកម្មឧត្តមសិក្សា (Chet et al., 2022; Sok & Bunry, 2021)។
- ប៉ុន្តែការស្រាវជ្រាវផ្ដោតលើតួនាទីសេវានិស្សិតលើការអភិវឌ្ឍនិស្សិតមិនទាន់ទទួលបានការយកចិត្តទុកដាក់ពេញលេញ និងកង្វះចន្លោះការស្រាវជ្រាវ។ ដូច្នេះ ការស្រាវជ្រាវបែបគុណវិស័យនេះមានគោលបំណងស្វែងរកពីគុណសម្បត្តិនៃសេវានិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។



# រំលឹកទ្រឹស្តី

# សង្ខេបសាវតាទ្រឹស្តីពាក់ព័ន្ធ

**1**

ទ្រឹស្តីការសិក្សាពីសង្គម ជាភាសាអង់គ្លេស Social Learning Theory ដែលបង្កើតឡើងដោយអ្នកចិត្តវិទូ Albert Bandura នៅឆ្នាំ១៩៧៧។

**2**

ទ្រឹស្តីគំរូសហមាហរណកម្មនិស្សិត ជាភាសាអង់គ្លេស Student Integration Model បង្កើតឡើងដោយអ្នកជំនាញសេវានិស្សិតដ៏ល្បីល្បាញគឺ Vincent Tinto នៅឆ្នាំ១៩៧០។

**3**

ទ្រឹស្តីអភិវឌ្ឍនិស្សិត ជាភាសាអស់គ្លេស Student Development Theory បង្កើតឡើងដោយនៅពាក់កណ្តាលសតវត្សទី២០ ដោយអ្នកចិត្តវិទូ និងបញ្ញវន្តផ្នែកឧត្តមសិក្សា។

# សង្ខេបអត្ថបទស្រាវជ្រាវ/ឯកសារពាក់ព័ន្ធ

- អង្គការពិភពលោក បញ្ញវន្ត អ្នកជំនាញ អ្នកស្រាវជ្រាវលើសេវានិស្សិតបានកំណត់ជាបន្តបន្ទាប់នូវគុណតម្លៃស្នូលមួយចំនួនដែលមិនអាចខ្វះបានក្នុងការជួយវដ្តនិស្សិតនៅឧត្តមសិក្សា(UNESCO, 2009) ប្រឹក្សាយោបល់ (Long, 2012) គាំពារនិស្សិតនិងគ្រឹះស្ថាន (Yong, 2003) ផ្សារភ្ជាប់សហគមន៍ (Roberts, 1993; Margolis & March, 2008; Vivian, 2005) និងការលើកកម្ពស់សមភាព និងយុត្តិធម៌សង្គម (Rickard, 1993)។
- ការផ្តល់ប្រឹក្សាផ្នែកសិក្សា (Gordon et al., 2011; Light, 2001) តម្រង់ទិសសិក្សានិងការចុះឈ្មោះចូលរៀន (Margolis & March, 2008) ណែនាំបរិវេណគ្រឹះស្ថាន (Astin et al., 2004) សុវត្ថិភាពនិងសន្តិសុខ (Long, 2012) ប្រឹក្សាអាជីព (Ciobanu, 2013) ធ្វើដំណើរ (Komarraju et al., 2020) សេវាសហគមន៍ (Sidanius et al., 2004) ជំនួយនិស្សិតពិការភាព (Seale, 2006) សុខភាព (Moeurn, 2025a) សេវាកម្មលំនៅដ្ឋាន (Conneely, 2002) ប្រឹក្សាច្បាប់ (Nuss, 2003) បណ្តុះបណ្តាលភាពអ្នកដឹកនាំ (Hall & Ponton, 2005; Menke et al., 2018) ពហុវប្បធម៌ (Gurin et al., 2002) កម្មវិធីសិក្សា (Johnson et al., 2008) ការកម្សាន្តនិងកីឡា (Kilchenman, 2009) និងសុខភាពផ្លូវចិត្ត (Hinchliffe & Wong, 2012) ជាដើម។

# ក្របខណ្ឌទ្រឹស្តីតួនាទីសេវានិស្សិតនៅកម្ពុជា




រូបភាពទី៣.៖ តួនាទីសេវានិស្សិតក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា (ប្រភព៖ការសំយោគឯកសារពាក់ព័ន្ធដោយអ្នកស្រាវជ្រាវ)



# វិធីសាស្ត្រ

# សង្ខេបវិធីសាស្ត្រ

ប្រើប្រាស់វិធីសាស្ត្រគុណវិស័យ (Creswell, 2012; Patton 2002) និងគ្រឹះស្ថាន៩មានទីតាំងនៅស្រាវជ្រាវនៅរាជធានីភ្នំពេញ (MoEYS, 2025)។

សំណាកចំនួន៩៧នាក់ តាមវិធីសាស្ត្រលក្ខណៈវិនិច្ឆ័យជាមុនមកពី៧ក្រុមពាក់ព័ន្ធ (Creswell, 2013; Denzin និង Lincoln (2011) ។



សម្ភាសន៍ពាក់កណ្ដាលព្រាងទុកដោយជ្រើសរើសទម្រង់ម្នាក់ទល់ម្នាក់ និងការសម្ភាសជាក្រុម (Cohen et al., 2007; Fraenkel et al., 2012; Schostak, 2006)។

សំណាកកំណត់ពេលនិងទីកន្លែង។ រយៈពេលចាប់ពី ៤៥ ទៅ ៩៥នាទី។ វិភាគតាមប្រធានបទ ដោយវិធី Abductive Analysis (Creswell & Creswell, 2018; David, 2017; Miles et al., 2020; Sharan, 2002) ។



# លទ្ធផលនិងពិភាក្សា

# តារាងទី១÷ សង្ខេបការពិភាក្សាតួនាទីសេវានិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា

| តួនាទីសំខាន់ៗ | សម្រង់សម្ដី | ការពិភាក្សា |
|---|---|---|
| ជំនាញ | ធ្វើឱ្យយើងមានអារម្មណ៍ចង់រៀន ព្រោះសាលាបារម្ភពីយើងជួយពង្រឹងសមត្ថភាពនិយាយនិងជំនាញតាមរយៈសកម្មភាពផ្សេង។ FGD២ | ស្របទ្រឹស្ដីការសិក្សាពីសង្គម Bandura (1977) បង្ហាញថានិស្សិតទទួលបានឱកាសរៀនសូត្រពីបរិស្ថានជុំវិញ។ ស្រដៀងគ្នានឹងរបាយការណ៍ស្ថាប័នអប់រំពិភពលោក រាជរដ្ឋាភិបាល លទ្ធផលស្រាវជ្រាវវិទ្យាសាស្ត្របង្ហាញថាបង្កើនជំនាញ(Abiola & Paul, 2019; Morgan et al., 2019; UNESCO, 2009) ព័ត៌មានសិក្សាច្បាស់លាស់ (Kutlu, 2004; Rovai & Downey, 2010) វិធីនិងយុទ្ធសាស្ត្ររៀនសូត្រ (Jacobs, 2009) រៀបចំផែនការសិក្សា (ACC, 2023; Niemi et al., 2016) បង្កើនសមត្ថភាព (Blaney et al., 2009) តម្រង់ទិសការសិក្សា (Ciobanu, 2013) លើកម្ពស់ភាសាអង់គ្លេស (Ntirenganya et al., 2026) និងជួយដល់និស្សិតរៀនខ្សោយ និងរៀនយឺតផងដែរ (Grillo & Leist, 2013) ។ |
| សមត្ថគុណចាំបាច់ | សេវានិស្សិតល្អធ្វើឱ្យនិស្សិតចូលសាលាទទួលអារម្មណ៍សប្បាយពេញចិត្តចង់ចូលរៀនជាជាងចូលក្លឹប។ ជីវិតនិស្សិតត្រូវការសាកលវិទ្យាល័យជួយអភិវឌ្ឍជីវិតគាត់។ R២ | ស្របលទ្ធផលស្រាវជ្រាវពីមានអាទិ៍ជួយប្រឹក្សាផ្លូវចិត្ត (Bowles et al., 2011; Lee & Choi, 2011) បញ្ហាស្ត្រី (Davie, 2009; UNESCO, 2009) ចំណេះដឹងហិរញ្ញវត្ថុ (Yasmin et al., 2024) ថែទាំងសុខភាព (Poertner, 2009) កន្លែងស្នាក់នៅ (Brown, 2016) កម្មវិធីអាហារូបករណ៍ (Duniway, 2012; Ganem, 2011) និងការសម្របខ្លួននៅទីតាំងថ្មី (Azfredrick, 2015) ។ លទ្ធផលនេះ បានរួមចំណែកយ៉ាងសំខាន់សម្រាប់និស្សិតកម្ពុជាមួយចំនួនដែលពុំទាន់បានរៀបចំផែនការសិក្សាបានត្រឹមត្រូវ ជាពិសេសនិស្សិតមកពីគ្រួសារក្រីក្រនិងតំបន់ដាច់ស្រយាលដែលទាមទារឱ្យមានការចូលរួមគាំទ្រពីគ្រឹះស្ថានឧត្តមសិក្សា។ |

| តួនាទីសំខាន់ៗ | សម្រង់សម្ដី | ការពិភាក្សា |
|---|---|---|
| **ផែនការអាជីព** | បើអត់មានផ្នែកប្រឹក្សាការងារទេ និស្សិតរៀនចប់ទៅក៏មិនដឹងទៅរកការងារធ្វើបានឬអត់ទេ...បើគណនេយ្យឱ្យនិស្សិតស្គាល់ក្រុមហ៊ុនឱ្យបានច្រើន។ មានក្លឹប ទស្សនកិច្ចសិក្សាតាមក្រុមហ៊ុនទៀត និងមានអញ្ជើញមកធ្វើកម្មវិធីនៅសាកលដើម្បីភ្ជាប់និស្សិតទៅនឹងការងារ។ ពេលមករៀនគាត់មានសេវាគាំទ្ររៀន ក្នុងថ្នាក់គាត់មានជំនាញហើយគាត់មានទំនាក់ទំនងជាមួយវិស័យឯកជនទៀតដល់ពេលឆ្នាំទី៣ និងឆ្នាំទី៤គាត់រួចរាល់សម្រាប់ការងារ។ R៨ | ការផ្ដល់សេវាប្រឹក្សាការងារតាមរូបភាពជាច្រើនរួមមានការប្រឹក្សាផ្ទាល់ វគ្គបណ្ដុះបណ្ដាល កម្ម-វិធីហាត់ការ និងសកម្មភាពក្រៅថ្នាក់រៀនជាច្រើនទៀតជួយនិស្សិតអភិវឌ្ឍអាជីព និងបន្តកសាងផែនការបានត្រឹមត្រូវ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ លទ្ធផលនៃការសិក្សានេះស្របទៅនឹងការលើកឡើងពីអង្គភាពទទួលបន្ទុកអប់រំ និងលទ្ធផលស្រាវជ្រាវជា ច្រើនផងដែរ។ ជួយនិស្សិតចេះរៀបចំគោលដៅការងារ (ACC, 2009, 2023) ផែនការអាជីពច្បាស់លាស់ (Himelstein, 1992; Ribchester & Mitchell, 2004) ការរៀបចំខ្លួនបានត្រឹមត្រូវ (Husseiny, 2009; Moeurn, 2025a) និងលក្ខខណ្ឌការងារ (Wallace & Rachinger, 2009)។ និស្សិតត្រូវការប្រឹក្សា និងបំពេញបន្ថែម ដើម្បីស្របតាមតម្រូវការទីផ្សារការងារ។ |
| **ជំនាញទន់** | សកម្មភាពក្នុងសាលាក្ដី សកម្មភាពនៅក្នុងសង្គមក្ដី ឱ្យគាត់ចេះធ្វើការជាមួយគ្នា។ គាត់មានទំនាក់ទំនងល្អជាមួយសង្គម។ R១ | លទ្ធផលនេះស្រដៀងគ្នាទៅនឹងការស្រាវជ្រាវមួយចំនួនដោយជួយបង្កើនជំនាញទំនាក់ទំនង (Moeurn, 2025a) ដោះស្រាយបញ្ហា (Husseiny, 2009) បង្កើនទំនុកចិត្ត (Bateson & Taylor, 2004)។ ការកសាងជំនាញទន់បានក្លាយជាប្រធានបទសំខាន់ ជាពិសេសសម្រាប់និស្សិតមួយចំនួនដែលនៅពុំទាន់បានផែនការច្បាស់លាស់ និងពុំបានរៀបចំខ្លួនបានរួចរាល់។ ជាក់ស្ដែងការបង្ហាញទស្សនៈការងាររបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ (2024, 2025, 2026) អង្គការអន្តរជាតិខាងការងារ (2021) វេទិកាសេដ្ឋកិច្ចពិភពលោក (2024) និងទីភ្នាក់ងារជាតិមុខរបរនិងការងារ (2020) បានបង្ហាញពីកង្វះជំនាញទន់របស់បុគ្គលិក ផ្ដល់ឧបសគ្គដល់ដំណើរការងារអង្គភាពទាំងមូល និងសង្វាក់ផលិតកម្ម។ |

| តួនាទីសំខាន់ៗ | សម្រង់សម្ដី | ការពិភាក្សា |
|---|---|---|
| **បន្ថយបោះបង់ការសិក្សា** | ការជួយនិស្សិតភ្លាមៗធ្វើឱ្យនិស្សិតមានអារម្មណ៍ថាសាលាមើលថែគាត់ សាលាយកចិត្តទុកដាក់មកលើគាត់។ ការរៀនរបស់និស្សិតត្រូវការសេវាផ្ដល់ឱ្យនិស្សិតត្រឹមត្រូវ និស្សិតរៀនដោយសប្បាយចិត្ត និងចង់មករៀន។ R២០ | លទ្ធផលឆ្លើយតបនឹងទ្រឹស្ដីគំរូសហមាហរណកម្មនិស្សិតរបស់ Tinto (1970) ដែលបានបង្ហាញការការផ្ដល់សេវាគាំទ្រជំរុញឱ្យនិស្សិតមានកម្លាំងចិត្តខ្ពស់ ស្រឡាញ់គ្រឹះស្ថានសិក្សា និងងាយសម្របខ្លួនទៅនឹងបរិស្ថានថ្មី បន្ថយភាពឯការ និងកណ្ដោចកណ្ដែង។ ស្រដៀងនឹងការស្រាវជ្រាវវិទ្យាសាស្ត្ររួមមានការរៀបចំសកម្មភាពក្រៅថ្នាក់ (Tinto, 2025) ផ្ដល់ការប្រឹក្សា (Goncxalves et al., 2024) បរិយាកាសងាយស្រួលក្នុងការសិក្សា (Moeurn, 2025a) អារម្មណ៍រីករាយ (Ginsberg & Wlodkowski, 2009) ស្មារតីគ្រឹះស្ថានជារបស់ពួកគាត់ (Frick et al., 2009; Tessema et al., 2012) លើកទឹកចិត្ត (Lotkowski et al., 2004) និងការបង្កើនសកម្មភាពចូលរួម (Kajoina,2022) ។ លទ្ធផលទាំងនេះបង្ហាញពីគុណតម្លៃសេវានិស្សិតជួយបន្ថយការបោះបង់ការសិក្សា។ |
| **ការទទួលខុសត្រូវសង្គម** | ពេលនិស្សិតបានចុះការងារសង្គមគាត់ដឹងពីសុខទុក្ខ និងតម្រូវការផ្ទាល់របស់ប្រជាពលរដ្ឋ។ ជាពិសេសសកម្មភាពនេះបានជំរុញឱ្យគាត់ពីតួនាទី ជាអ្នកបន្តវេនគឺត្រូវរៀបចំផែនការ និងសកម្មភាពជួយដល់ប្រជាពលរដ្ឋ។ និស្សិតនឹងឃើញផ្ទាល់បន្ថែមពីការសិក្សាក្នុងថ្នាក់ពីការទទួលខុសត្រូវរបស់គាត់ក្នុងសង្គម។ ពិតណាស់ថាសង្គមសំខាន់ណាស់ ដែលយើងជាពលរដ្ឋត្រូវការពារឱ្យខានតែបានទោះក្នុងរូបភាពណាក៏ដោយ។ R១៨ | លទ្ធផលនេះ ស្រដៀងគ្នាទៅនឹងលទ្ធផលនៃការស្រាវជ្រាវជាច្រើនដូចជាចំណេះដឹងក្នុងសង្គម (UNESCO, 2022) ជំរុញការយល់ដឹងពីកិច្ចសហការក្រុម (Lopes, 2015) ការកែលម្អសង្គម Villaeys et al., 2009) ចូលរួមក្នុងសហគមន៍ (Vlaar, 2009) ពលរដ្ឋសកម្ម (Subagyo & Silalahi, 2014; Zgaga, 2019) និងការទទួលខុសត្រូវសង្គម (UNESCO, 2002) ។ ការទទួលខុសត្រូវសង្គមរួមចំណែកយ៉ាងសំខាន់ក្នុងការបណ្ដុះនូវស្មារតីដល់និស្សិតគឺជាចំណែកមួយនៃដំណោះស្រាយ ដោយរៀចាកការបង្កបញ្ហាដល់សង្គមដែលយើងកំពុងរស់នៅ។ ទន្ទឹមនេះ ស្មារតីនេះមានតម្លៃជាខ្លាំងសម្រាប់ប្រទេសកំពុងអភិវឌ្ឍដែលត្រូវការសាមគ្គីភាព និងការទទួលខុសត្រូវនៃពលរដ្ឋម្នាក់ៗ ដើម្បីក្លាយជាសង្គមពុទ្ធិ ភាពធន់ និងរឹងមាំ។ |

| តួនាទីសំខាន់ៗ | សម្រង់សម្ដី | ការពិភាក្សា |
|---|---|---|
| អ្នកសិក្សាពេញមួយជីវិត | សាកលវិទ្យាល័យមានរៀបចំសកម្មភាពជាច្រើនក្នុងការរួមចំណែកលើកកម្ពស់ការសិក្សាជាប់ជាប្រចាំដល់និស្សិត។ ជាបទពិសោធន៍យើងមានរៀបចំការប្រកួតប្រជែងនានាជាដើម។ ការរៀបចំនេះគោលដៅបណ្ដុះស្មារតីឱ្យនិស្សិតបានយល់បន្ថែមពីគោលដៅ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងក្លាយខ្លួនជាអ្នករៀនសូត្រគ្រប់ពេល មិនមែនចប់សញ្ញាបត្រគឺត្រូវឈប់សិក្សានោះទេ។ R១០ | លទ្ធផលឆ្លើយតបនឹងទ្រឹស្ដីការអភិវឌ្ឍនិស្សិតកើតឡើង នៅពាក់កណ្ដាលសតវត្សទី២០ ផ្ដោត-សំខាន់ការរៀបចំសេវានិស្សិតឱ្យបានឆ្លើយតបទៅនឹងតម្រូវការនិស្សិត ដើម្បីធានាថានិស្សិតនឹងទទួលឱកាសប្រើប្រាស់សេវានិស្សិត ក្នុងគោលបំណងបង្កើនសមត្ថភាព។ លទ្ធផនេះស្រប នឹងរបាយការណ៍ និងលទ្ធផលស្រាវជ្រាវដូចជាបង្ហាញគំហើញថ្មី (World Bank, 2000) គំនិតផ្ដួចផ្ដើម (Viron & Davies, 2015) ភាពម្ចាស់ការលើការរៀន (UNESCO, 2015) និងផ្ដល់បរិយាកាសនិស្សិតរៀនជាប់ជាប្រចាំ(Carneiro, 2007)។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជា (2023) បានលើកទឹកចិត្តឱ្យនិស្សិតក្លាយជាអ្នកសិក្សាជាប់ជាប្រចាំ ឬអ្នកសិក្សាពេញមួយជីវិត ហើយសាកលវិទ្យាល័យដើរតួនាទីសំខាន់ក្នុងការគាំទ្រ និងផ្ដល់បរិយាកាសឆ្លើយតបទិសដៅនេះដល់និស្សិត (MoEYS, 2024)។ |
| ភាពជាខ្មែរ | សកម្មភាពជាច្រើនដែលយើងចូលរួមជាមួយស.ស.យ.កគឺបានជួយបណ្ដុះស្មារតីនិស្សិតឱ្យស្រឡាញ់ជាតិ ការពារជាតិ និងស្មារតីតែមួយក្នុងបុព្វហេតុជាតិ។ ជាក់ស្ដែង យើងធ្លាប់បានចូលរួម និងសហការដឹកនាំនិស្សិតចូលរួមកម្មវិធីសំខាន់ៗជាច្រើនរួមមានអង្គរសង្ក្រាន្ត និងសកម្មភាពក្រោមរូបភាពបង្ហាញសាមគ្គីភាពយុវជន ដើម្បីបុព្វហេតុជាតិជាដើម។ សកម្មភាពទាំងនេះឱ្យនិស្សិត កាន់តែយល់ច្បាស់ពីភាពជាខ្មែរ និងស្មារតីខ្មែរតែមួយ។ R២៦ | លទ្ធផលបញ្ជាក់ផងដែរថាការអភិវឌ្ឍភាពជាខ្មែរគឺជាដួងប្រលឹងជាតិ ដែលទាមទារឱ្យនិស្សិតឈរក្នុងសំឡេងតែមួយ និងមានសាគ្គីភាពផ្ទៃក្នុងរឹងមាំ។ លទ្ធផលនេះស្រដៀងគ្នាទៅនឹងការស្រាវជ្រាវមួយចំនួនដូចជាការលើកកម្ពស់អត្តសញ្ញាណជាតិ (Zgaga, 2019) ថែរក្សាប្រពីណីនិងវប្បធម៌ (RGC, 2002, 2023) មានស្មារតីស្រឡាញ់ជាតិ(Fildman, 1969; Lopes, 2015; Resch, 2018) និងមោទនភាពជាខ្មែរ (Moeurn, 2025a)។ សេវានិស្សិតបានរៀបចំសកម្មភាពសំខាន់ និងភាពចាំបាច់នៃសកម្មភាពមួយចំនួនបានរួមចំណែកក្នុងការរក្សាគុណតម្លៃ និងកិត្យានុភាពនៃពលរដ្ឋខ្មែរដល់និស្សិត។ |



# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ការស្រាវជ្រាវនេះមានគោលបំណងរកឱ្យឃើញពីតួនាទីសំខាន់ៗនៃសេវានិស្សិតនៅក្នុងគ្រឹះស្ថានឧត្ដមសិក្សាកម្ពុជា។

ការស្រាវជ្រាវរកឃើញថា សេវានិស្សិតអភិវឌ្ឍជំនាញ សមត្ថគុណចាំបាច់ ផែន-ការអាជីព ជំនាញទន់ បន្ថយបោះបង់ការសិក្សា ការទទួលខុសត្រូវសង្គម អ្នកសិក្សាពេញមួយជីវិត និងអភិវឌ្ឍភាពជាខ្មែរ។

គ្រឹះស្ថានឧត្ដមសិក្សា អ្នករៀបចំគោលនយោបាយអប់រំ និងក្រសួងអាណាព្យាបាលនៃគ្រឹះស្ថានឧត្ដមសិក្សា

ការសិក្សាមានដែនកំណត់មួយចំនួនដែលពុំអាចយកលទ្ធផលធ្វើទូទៅកម្ម និងស្នើការស្រាវជ្រាវបន្ទាប់។

# សូមអរគុណ


077 716 289 / 010 757 936

moeurn.chantrea.rupp@moeys.gov.kh


